# កម្មវិធីស្រ្តីក្នុងក្តីសង្ឃឹម

## មេរៀនជីវិតៈ ការសំលាប់ខ្លួន

## មេរៀនព្រលឹងវិញ្ញាណៈ ជីវិតគឺជាអំណោយទានដែលព្រះអោយដល់មនុស្សទាំងអស់

**បូផា:** ចាស សូមស្វាគមន៍បងប្អូនស្រ្តី ក្នុងការចូលរួមកម្មវិធីស្រ្តីក្នុងក្តីសង្ឃឹម។ **ចាស់** នៅសប្តាហ៍នេះ បងប្អូននៅតែជួបជាមួយខ្ញុំ បូផា និងណារី ដដែរ។ តើបងប្អូនសុខសប្បាយអត់?

**ណារី:** ចាស បង យើងសង្ឃឹមថា បងប្អូនស្រ្តីយើង សុខសប្បាយទាំងអស់គ្នា មែនទេបង?

**បូផា:** បងប្អូនស្រ្តី ថ្ងៃនេះខ្ញុំចង់និយាយពីរឿងមួយ ដែលកើតឡើងរួចមកហើយ ហើយរឿងនេះដូចជារៀងកើតទុក្ខបន្តិចហើយបងប្អូនស្រ្តី។

**ណារី:** ពេលលឺបងចង់និយាយរឿងកើតទុក្ខអញ្ចឹង ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្តសោះ។

**បូផា:** ចាស ពិតមែនហើយណារី និយាយមិនខុសទេ ពេលដែលយើងលឺរឿងរបស់នរណាម្នាក់ ទោះបីអ្នកនោះជាអ្នកដែលយើងស្គាល់ ឬ មិនស្គាល់ក៏ដោយ អោយតែជារឿងកើតទុក្ខ នោះធ្វើអោយអារម្មណ៍របស់យើងមិនសូវស្រួលប៉ុន្មានទេ។ ឧទាហរណ៍ ពេលយើងលឺថា មានស្រ្តីណាម្នាក់ចង់សំលាប់ខ្លួន ប្រាកដជាយើងដឹងហើយថា គាត់ប្រហែលមានការឈឺចុកចាប់អ្វីមួយហើយ ឬ ដោយសារតែបញ្ហាច្រើនពេកដែលកើតឡើងចំពោះជីវិតរបស់គាត់ ហើយយើងមិនអាចដឹងអោយច្បាស់ថា តើមកពីមូលហេតុអ្វីនោះទេ មែនទេ?

**ណាវី:** ចាស ពិតមែនហើយបង។ ខ្ញុំសង្កេតឃើញថា ចំនួនមនុស្សដែលសំលាប់ខ្លួន មានអត្រាកាន់តែច្រើនឡើងហើយ ហើយនេះជារឿងដែលគួរអោយព្រួយបារម្ភមែនទែន។

**បូផា:** ចាស មែនហើយអូន ប៉ុន្តែបងប្អូនស្ត្រី ដើម្បីកុំអោយអោយពេលវេលារបស់យើងកន្លងពេលហួសទៅច្រើនពេក សូមបងប្អូនស្ត្រី បានចូលរួមស្តាប់ជាមួយយើងក្នុងមេរៀនជីវិតដែលនិយាយពី ការសំលាប់ខ្លួន។

## មេរៀនជីវិត: ការសំលាប់ខ្លួន

**បូផា:** ចាស ណាវី ក៏ដូចជាបងប្អូនស្ត្រី យើងមើលឃើញថា ការដែរយើងក្រៀមក្រំចិត្ត ព្រួយចិត្ត តានតឹងចិត្ត អាចធ្វើអោយយើងមានអារម្មណ៍ថា ឈឺចាប់។ កាលណាអារម្មណ៍ កៀម ក្រំចិត្ត ព្រួយចិត្ត ឬ តានតឹងចិត្តកើតមានយូរ នោះនឹងធ្វើអោយយើងមានការអស់សង្ឃឹម អស់កម្លាំង និងល្វើយទៀតផង។ ចាស ណាវី ចឹងបានជាពេលដែលយើងមានអារម្មណ៍ទាំងអស់នោះនៅក្នុងខ្លួន នឹងធ្វើអោយយើងពិបាកក្នុងការរកវិធីដោះស្រាយ ដោយខ្លួន ឯង មែនទែន។

**ណាវី:** ចាស បងប្អូនស្ត្រី នៅថ្ងៃនេះ យើងខ្ញុំទាំងពីរនាក់ចង់និយាយពីការដែលមានចិត្តចង់សំលាប់ខ្លួន។ ហេតុអ្វីដែលជាមានអារម្មណ៍បែបនេះហ្ន៎?

**បូផា:** ចាស ណាវី ក៏ដូចជាបងប្អូនស្ត្រី យើងមើលឃើញថា មានមនុស្សជាច្រើន នៅពេលដែលពួកគាត់ជួបបញ្ហាជាច្រើន ដែលធ្វើអោយពួកគាត់មានអារម្មណ៍តានតឹងចិត្ត ពេលនោះពួកគាត់តែងតែប៉ុនប៉ងចង់សំលាប់ខ្លួនឯង ដើម្បីគេចវេសពីបញ្ហាទាំងអស់នោះ។

**ណារី:** ចាស ពិតមែនហើយបង។ ចាស បងប្អូនស្ត្រី កាលពីមុនមានបងស្រីម្នាក់ ក៏គាត់ធ្លាប់គិតចង់សំលាប់ខ្លួនដែរ ដោយសារតែបញ្ហាជាច្រើនធ្វើអោយខួរក្បាល និងចិត្តរបស់គាត់ឈឺចាប់មែនទែន ហើយគាត់គិតថា គាត់គ្មានអ្វីទាំងអស់ ហើយគ្មានអ្វីដែលសំខាន់សំរាប់ជីវិតរបស់គាត់ទៀតទេ។ ការឈឺចាប់ទាំងអស់នោះ គឺងាយស្រួលអោយគាត់ធ្លាក់ក្នុងគំនិតមួយគឺហ៊ានសំលាប់ខ្លួនឯងតែម្តង។ គាត់ធ្លាប់បានសូមព្រះអង្គអោយដកយក ជីវិតរបស់គាត់ទៅប៉ុន្តែទ្រង់មិនបានធ្វើដូច្នេះទេ។ ឥលូវគាត់សប្បាយចិត្តណាស់ ដែលនៅពេលនោះគាត់មិនបានសំលាប់ខ្លួន ព្រោះឥលូវនេះគាត់ដឹងថា ជីវិតគឺមានតំលៃមែនទែន ព្រោះជីវិតជាអំណោយរបស់ព្រះ។ ប៉ុន្តែ គាត់បានបន្តទៀតថា ពេលខ្លះគាត់នៅតែពិបាកតទល់ជាមួយគំនិតដែលចង់សំលាប់ខ្លួនណាស់ ពិសេសនៅពេលដែលគាត់មានអារម្មណ៍តានតឹងចិត្ត។

**បូផា:** ចាស បងប្អូនស្ត្រី តើអ្នកធ្លាប់មានអារម្មណ៍ដូចជាបងស្រីម្នាក់នោះអត់? ពីកម្មវិធីរបស់យើង សង្ឃឹមថាមេរៀននៅថ្ងៃនេះនឹងអាចជួយបងប្អូន ដើម្បីអោយបងប្អូនមានអារម្មណ៍ធូរស្រាលបាន។

**ណារី:** ចាស បងបូផា យើងមើលឃើញថា មនុស្សជាច្រើន បានសំលាប់ខ្លួនដោយសារតែភាពតានតឹងចិត្តរបស់ពួកគាត់កាន់តែធ្ងន់ទៅៗ។ តើបងប្អូនស្ត្រី គិតដូចជាខ្ញុំអត់?

**បូផា:** ចាស អូន មែនហើយ។ មនុស្សដែលមានអារម្មណ៍អស់សង្ឃឹមនៅក្នុងជីវិត គឺពួកគាត់ងាយស្រួលធ្លាក់ទៅក្នុងគំនិតដែលគិតថា គ្មានអ្វីដែលអាចផ្លាស់ប្រែជីវិត ឬ បញ្ហាដែលពួក

គាត់ជួបប្រទះ ហើយគាត់គិតថា មានតែវិធីមួយគត់ ដើម្បីបន្ធូរការឈឺចាប់ទាំងអស់ដែលគាត់មាន ដោយត្រូវបញ្ចប់ជីវិតរបស់ខ្លួនឯង។

**ណារី:** ចាស ពិតមែនហើយបង។ ចឹងបងប្អូនស្រ្តី យើងខ្ញុំទាំងពីរមានសំនួរខ្លះៗ ហើយសូមបានឆ្លើយសំនួរទាំងអស់នេះ ដោយខ្លួនឯង ហើយដោយស្មោះត្រង់ផងដែរ។ តើបងប្អូនធ្លាប់មានអារម្មណ៍ចង់សំលាប់ខ្លួនអត់?

**បូផា:** តើបងប្អូនធ្លាប់រៀបគំរោងការណ៍ដើម្បីសំលាប់ខ្លួនអត់?

**ណារី:** តើបងប្អូនធ្លាប់ញែកពេលណាមួយ ដើម្បីអោយបងប្អូនអាចសំលាប់ខ្លួនបាន?

**បូផា:** តើអ្នកចង់ប្រើអ្វី ដើម្បីមកសំលាប់ខ្លួន? ចាស ប្រសិនបើចំលើយរបស់បងប្អូនធ្លាប់ទាំងអស់នោះ សូមបងប្អូនបានបញ្ឈប់គំនិតទាំងអស់នោះចេញ។ បងប្អូនស្រ្តី យើងខ្ញុំចង់អោយបងប្អូនចំណាយពេលគិតបន្តិចថា បើសិនជាអ្នកគិតខ្លី មិនមែនជាបងប្អូន តែជាម្នាក់ដែលបងប្អូនដែលជិតខាងបងប្អូន ឬ ជាមនុស្សដែលជាទីស្រលាញ់របស់បងប្អូនវិញ តើបងប្អូនមានអារម្មណ៍បែបណា? បងប្អូនប្រហែលជា យំ សោកស្តាយ ហើយមែនទេ? ចាស ដូចគ្នានេះផងដែរ ប្រសិនជាបងប្អូនគិតខ្លី ឬ សំលាប់ខ្លួន នោះអ្នកជុំវិញយើងក៏មានអារម្មណ៍ដូចជាយើងដែរ។

**ណារី:** ចាស បងប្អូនស្រ្តី នៅពេលនេះ អ្វីដែលខ្ញុំចង់អោយអ្នកបានយល់ថា មានពេលខ្លះជីវិតរបស់យើងក៏មានពេលដែលប្រសើរឡើងដែរ ដូចថា មិនមែនជួបបញ្ហាគ្រប់ពេលនោះទេមែនទេបង?

**បូផា:** ចាស ពិតមែនហើយអូន។ បងប្អូនស្ត្រី ប្រសិនបើជីវិតអាចប្រសើរឡើងចំពោះខ្ញុំ នោះវាក៏អាចប្រសើរឡើងចំពោះអ្នកផងដែរ។ ទោះបីជាពេលនេះ ខ្ញុំមិនដឹងថា អ្នកឆ្លងកាត់នូវការលំបាកខ្លាំងយ៉ាងណានៅពេលនេះក៏ដោយ តែខ្ញុំដឹងថា មានការខ្លះអាចជួយដោះស្រាយបញ្ហារបស់អ្នក អោយបានប្រសើរឡើងផងដែរ។

**ណារី:** ចាស បង នៅពេលដែលបងមានការតានតឹងចិត្តដោយសារបញ្ហាអ្វីមួយ តើយើងត្រូវធ្វើយ៉ាងម៉េចទៅ?

**បូផា:** ចាស ណារី ក៏ដូចជាបងប្អូនស្ត្រី នៅពេលដែលបងប្អូនមានភាពតានតឹងចិត្តខ្លាំង បងប្អូនកុំបណ្តោយខ្លួនរបស់អ្នកធ្លាក់ ដល់កំរិតដែលមិនអាចគ្រប់គ្រងខ្លួនឯងមិនបាននោះឡើយ។ បងប្អូនគួរតែចែកចាយអ្វីដែលនៅក្នុងចិត្តគំនិតរបស់អ្នកទៅកាន់នរណាម្នាក់ដែលអ្នកគិតថា គេចង់ស្តាប់ពីអ្នក ហើយអ្នកនោះគឺជាម្នាក់ដែលអ្នកទុកចិត្តបាន។ ណារី ចំពោះបង នៅពេលដែលខ្ញុំជួបបញ្ហាជាច្រើន មុនដំបូងខ្ញុំមិនហ៊ានប្រាប់នរណាម្នាក់ទេ តែលុះដល់ពេលមួយដែលខ្ញុំមិនអាចទ្រាំទ្របាន ធុញទ្រាំច្រើន ហើយហាក់ដូចជាមិនឃ្លានអ្វី នោះខ្ញុំគិតថា ខ្ញុំពិតជាត្រូវការនរណាម្នាក់ ដើម្បីចែកចាយពីអារម្មណ៍នោះចេញ។ បងពិតជាអរគុណព្រះអង្គមែនទែន ដែលទ្រង់បានអោយបងមានមិត្តល្អៗ។ ពួកគាត់ជួយលើកទឹកចិត្ត និងស្តាប់ពីចិត្ត និងអារម្មណ៍របស់ខ្ញុំ។ ពេលដែលខ្ញុំនិយាយចេញពីអារម្មណ៍ខ្ញុំហើយ ខ្ញុំមានអារម្មណ៍ថា ដូចជាបានរសាយចិត្តខ្លះៗ ហើយខ្ញុំពិតជាចង់អរគុណ ដល់ពួកគាត់មែនទែនដែលបានស្រលាញ់រាប់អានខ្ញុំ។ ចុះណារីវិញ?

**ណារី:** ចាស បងនៅពេលដែលខ្ញុំមានសំពាធអារម្មណ៍ ដូចជាតានតឹង ខ្ញុំក៏បានចែកចាយអ្វីដែលមានក្នុងចិត្តខ្ញុំប្រាប់ដល់មិត្តល្អខ្ញុំម្នាក់នោះ។ បន្ទាប់ពីខ្ញុំចែកចាយហើយ គាត់បានសួរសំនួរជាច្រើន ព្រោះគាត់ចង់ជួយខ្ញុំអោយផ្លាស់ប្តូរគំនិតមិនល្អខ្លះៗចេញ។

**បូផា:** ចាស បងប្អូនស្ត្រី ប្រហែលជាពេលខ្លះ បងប្អូនប្រហែលជាបន្ទោសខ្លួនឯង ហើយគិតថាខ្លួនមិនល្អ ធ្វើអ្វីក៏មិនបានសំរេច គឺបរាជ័យរហូត មែនទេ? ចាស ប្រហែលជាបងប្អូនគិតថា ខ្លួនមិនល្អ ដោយសារអ្នកនៅជុំវិញអ្នកបានធ្វើអោយអ្នកគិតថាខ្លួនអន់ គ្មានប្រយោជន៍ ហើយធ្វើអ្វីក៏មិនកើត។ ចាស ហើយសំលេងទាំងអស់នេះ អាចធ្វើអោយអ្នកពិបាកទទួលមែនទែន ហើយវាថែមទាំងបំផ្លាញអារម្មណ៍ល្អដែលអ្នកមានចំពោះខ្លួនឯងទៀតផង។

**ណារី:** តែជាការសំខាន់ គឺនៅពេលដែលសំលេងទាំងអស់នោះ ចូលក្នុងត្រចៀកបងប្អូន បងប្អូនត្រូវផាក់វាចេញ ហើយសូមតតាំងនឹងវា និងប្រឈមមុខនឹងការពិតផងដែរ។ តែបងប្អូនស្ត្រី នៅពេលដែលបងប្អូនធ្វើអ្វីមិនបានសំរេច នោះមិនមែនមានន័យថា បងប្អូនជាមនុស្សមិនល្អនោះទេ ព្រោះយើងត្រូវតែដឹង និងយល់ពីតំលៃរបស់ខ្លួនផងដែរ គឺព្រះបានបង្កើតយើងមកពិសេសមែនទែន គ្មាននរណាម្នាក់ដូចជាយើងនោះទេ ដ្បិតទ្រង់ស្រលាញ់អ្វីដែលទ្រង់បានបង្កើតមក ដូច្នេះសូមយើងកុំបំផ្លាញការបង្កើតរបស់ទ្រង់អោយសោះ ព្រោះទ្រង់ស្រលាញ់អ្នកខ្លាំងមែនទែនគឺលើសមនុស្សទាំងអស់ដែលបានស្រលាញ់យើង។

**បូផា:** ចាស ណារី ក៏ដូចជាបងប្អូនស្ត្រី តាមការស្រាវជ្រាវបានអោយយើងដឹងថា មានមនុស្សជាច្រើនដែលប៉ុនប៉ងសំលាប់ខ្លួន ព្រោះពួកគេចង់អោយការឈឺចាប់របស់គេបានបញ្ចប់។ បងប្អូនស្ត្រី អារម្មណ៍បែបនេះ ប្រហែលជាអ្នកកំពុងតែមាននៅពេលនេះផងក៏មិនដឹង។ ខ្ញុំក៏ធ្លាប់មានអារម្មណ៍ដូចជាបងប្អូនដែរ តែខ្ញុំមិនដែរគិតចង់សំលាប់ខ្លួនទេ តែខ្ញុំគ្រាន់តែចង់រំសាយនៅអារម្មណ៍ ដែលពេញទៅដោយការឈឺចាប់តែប៉ុណ្ណោះ។

**ណារី:** ចាស បងប្អូនស្ត្រី ដូច្នេះវិធីដែលអាចនាំអោយបងប្អូនអាចរំសាយភាពស្មុគស្មាញ និងការឈឺចាប់នៅក្នុងអារម្មណ៍របស់អ្នកបាននោះគឺ

**ទី១** សូមនិយាយទៅកាន់ព្រះ និងសូមជំនួយពីព្រះអង្គ។ នៅក្នុងព្រះគម្ពីរ ទំនុកតំកើង ៤៦:១ ទ្រង់មានបន្ទូលថា″ **ព្រះជាម្ចាស់ទ្រង់ជាជំរក និងជាបង្អែកដ៏រឹងមាំរបស់យើង នៅពេលមានអាសន្ន ព្រះអង្គតែងតែប្រុងប្រៀបចាំជួយយើងជានិច្ច។**″ បងប្អូនស្ត្រី ព្រះនៅជាប់ជាមួយអ្នកនៅពេលដែលអ្នកមានបញ្ហាស្មុគស្មាញ គិតអ្វីមិនចេញ។

**បូផា: ទី២** សូមអោយអ្នកស្វែងរកនរណាម្នាក់ ដែលអ្នកទុកចិត្ត ហើយអ្នកនោះជាម្នាក់ដែលចង់ស្តាប់អ្នក និងជួយអ្នក។ វិធីចុងក្រោយ បើអ្នកអាចទៅរួច គឺ ទៅជួបពិភាក្សាជាមួយគ្រូពេទ្យ ដើម្បីសុំយោបល់ពីគាត់ តើអ្នកគួរប្រើថ្នាំជំនួយឬអត់ ព្រោះមានថ្នាំពេទ្យមួយចំនួនក៏ជាផ្នែកមួយដែលជួយសំរួលខួរក្បាល របស់អ្នកអោយមានដំណើរការល្អឡើងវិញដែរ។

**ណារី:** ចាស បងប្អូនស្ត្រី បើសិនជាបងប្អូននៅតែមានបញ្ហាក្រៀមក្រំចិត្ត ហើយតានតឹងទៀតនោះ ខ្ញុំសូមលើកទឹកចិត្តបងប្អូនម្តងទៀត សូមទៅរកនរណាម្នាក់ដែលអាចជួយសំរាលភាព

តានតឹងរបស់អ្នកបាន។ ពិសេសចំពោះបងប្អូនស្រ្តីនៅក្នុងក្រុមជំនុំ អាចទៅសាកសួរយោបល់ពីគ្រូគង្វាល ចាស់ទុំ ឬបេសកជនណាមួយណាមួយដែលបងប្អូនគិតថា ពួកគាត់អាចទុកចិត្តបាន។

**បូផា:** ចំពោះបងប្អូនដែលរស់នៅភ្នំពេញ បងប្អូនអាចទៅជួបជាមួយគ្រូពេទ្យចិត្តសាស្រ្ត ដើម្បីទទួលយោបល់ពីពួកគាត់ផងដែរ។ បងប្អូនស្រ្តី តើពេលនេះ អ្នកអាចសន្យាជាមួយយើងខ្ញុំបានទេថា អ្នកត្រូវថៃទាំសុខភាពរបស់អ្នកជាសំខាន់ សូមតស៊ូ និងប្រឆាំងជាមួយនឹងគំនិតដែលធ្វើអោយបងប្អូនឈឺចាប់ និងដកការតានតឹងនោះចេញពីអារម្មណ៍របស់អ្នក។

**ណារី:** ចាស បងប្អូនស្រ្តី ជីវិតគឺមានតំលៃ ដូច្នេះ បើយើងត្រូវស្លាប់ក៏ត្រូវស្លាប់អោយមានតំលៃដែរ។ ចាស មេរៀនជីវិតរបស់យើងនៅថ្ងៃនេះ បានចប់សព្វគ្រប់ហើយ ហើយមុននឹងបន្តមេរៀនព្រលឹងវិញ្ញាណ សូមបានសំរាកស្តាប់ជាមួយនឹងបទចំរៀងមួយបទសិន។ ចាស សូមអញ្ជើញ

…………………………………………**ចំរៀង**………………………………………..

**មេរៀនព្រលឹងវិញ្ញាណ: ជីវិតគឺជាអំណោយទានរបស់ព្រះសំរាប់មនុស្សទាំងអស់**

**បូផា:** ចាស បងប្អូនស្ត្រី តើមាននរណាម្នាក់ធ្លាប់ប្រាប់បងប្អូនថា អ្នកមានតំលៃណាស់នៅក្នុងព្រះនេត្រព្រះជាម្ចាស់? ជាការពិតណាស់ ព្រះទ្រង់ស្រលាញ់អ្នក ហើយអ្នកមានតំលៃណាស់ចំពោះទ្រង់។ ចាស ណារី មានស្ត្រីជាច្រើន តាំងពីកើតមកត្រូវទទួលរងនូវការធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្ត ពីសំណាក់អ្នកដែលនៅជុំវិញខ្លួនពួកគាត់ ហើយក៏មានអ្នកខ្លះទៀតត្រូវឪពុកម្តាយបោះបង់ គឺតាំងពីមិនទាន់កើតមកម្ល៉េះ។

**ណារី:** ចាស បងប្អូនស្ត្រី នៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ដែលនៅក្នុង ព្រះគម្ពី រ អេសាយ ៤៩ :១៥-១៦ " **តើម្តាយអាចបំភ្លេចកូនដែលនៅបៅដោះបានឬ? តើ ម្តាយលែងអាណិតមេត្តាកូនដែលកើតចេញពីផ្ទៃរបស់ខ្លួនបានឬ? ឧបមាថា ម្តាយបំភ្លេចកូនបានទៅចុះ ចំណែកឯយើងវិញ យើងមិនអាចភ្លេច អ្នក បាន ឡើយ! យើងបានចារឈ្មោះរបស់អ្នកនៅលើបាតដៃរបស់យើង ហើយយើង តែងតែនឹកគិតដល់កំពែងរបស់អ្នកជានិច្ច។**

**បូផា:** ចាស បងប្អូនស្ត្រី មានឃើញអត់ថា ទោះបីគេថា អ្នកជាមនុស្សមិនបានការក៏ដោយ ឬគេមិនស្រលាញ់ មិនចូលចិត្ត តែសូមចាំថា ព្រះយេស៊ូស្រលាញ់អ្នក។ ជីវិតរបស់អ្នកមានតំលៃណាស់ចំពោះទ្រង់ ព្រោះទ្រង់បានបង្កើតអ្នកមក ទ្រង់មានគោលបំណងមួយ ដូច្នេះជីវិតអ្នកគឺជាអំណោយដែលមកពីព្រះ។ នេះជាការពិត ហើយវាជាហេតុផលគ្រប់គ្រាន់មួយសំរាប់យើងគ្រប់គ្នា ដើម្បីជ្រើសរើសជីវិត និងមានជីវិតរស់នៅ។

**ណារី:** ចាស បងប្អូនស្ត្រី ពេលនេះ ប្រហែលជាលើកទីមួយសំរាប់បងប្អូនហើយ ដែលលឺថាព្រះស្រលាញ់អ្នកដោយគ្មានល័ក្ខខណ្ឌ។ ប្រហែលជាពេលនេះ អ្នកកំពុងខកចិត្តនឹងរឿងអ្វី

មួយ ហើយបងប្អូនចាប់ផ្តើមមិនពេញចិត្តនឹងជីវិត ដូច្នេះវាធ្វើអោយអ្នកចង់ស្លាប់ ដើម្បីបញ្ចប់បញ្ហា។

**បូជាៈ** បងប្អូនស្រ្តី សូមកុំគិតដូច្នេះអី កុំប្រថុយសំលាប់ខ្លួនអោយសោះ ព្រោះជីវិតដែលពោរពេញដោយអំណរកំពុងរងចាំអ្នក ទោះបីអ្នកជួបហេតុការណ៍ពិបាកនៅក្នុងជីវិតយ៉ាងណាក៏ដោយ ព្រះមានអំណាចអាចបំផ្លាស់ហេតុការណ៍ទាំងអស់នោះបាន ហើយទ្រង់នឹងប្រទានអនាគតដ៏ភ្លឺស្វាងដល់អ្នក។

**ណារីៈ** ចាស បងបូជា ប្រហែលជាមានបងប្អូនរបស់យើងមួយចំនួនគាត់គិតថា តើធ្វើម៉េចទៅដើម្បីធ្វើអោយការទាំងអស់នោះអាចកើតឡើងបាន?

**បូជាៈ** ចាស បងប្អូនស្រ្តី សូមអោយខ្ញុំបានប្រាប់អ្នកសិនថា ហេតុអ្វីទ្រង់ចង់ផ្លាស់ប្រែហេតុការណ៍ទាំងប៉ុន្មាននៅក្នុងជីវិតអ្នក។ បងប្អូនស្រ្តី ព្រះទ្រង់ជាប្រភពនៃជីវិត ទ្រង់ស្រលាញ់ការមានជីវិតរស់ មិនមែនការស្លាប់នោះទេ។ នៅក្នុងព្រះគម្ពីរ ទ្រង់បានដាក់បញ្ញត្តិទាំងដប់ប្រការរបស់ទ្រង់ ដែលបានចែងថា " កុំអោយសំលាប់មនុស្សអោយសោះ"។ នេះមានន័យថា អ្នកមិនត្រូវសំលាប់មនុស្សណាម្នាក់ឡើយ ហើយក៏មិនត្រូវសំលាប់ខ្លួនឯងដែរ ព្រោះខ្លួនយើងក៏ជាមនុស្សដែរ។

**ណារីៈ** ផ្ទុយទៅវិញ យើងចាំបាច់ត្រូវថ្វាយជីវិតរបស់យើងទៅទ្រង់វិញ ហើយនៅពេលនោះទ្រង់នឹងជួយយើង។ ទ្រង់នឹងប្រទាននូវក្តីអំណររបស់ទ្រង់ ហើយនិងកម្លាំង ដើម្បីអោយយើងអាចមានជីវិតរស់ទៅទៀត ទោះបីជាយើងមានអារម្មណ៍ចង់ស្លាប់ក៏ដោយ។

**បូផា:** ចាស ជាការពិតណាស់ ព្រោះថា នៅពេលដែលព្រះបង្កើតមនុស្សមក ទ្រង់ផ្ដល់អោយគេនូវព្រលឹង វិញ្ញាណ និងរាងកាយ។ ទ្រង់បានប្រទានដល់អាដាំនិងអេវ៉ា នូវរូបកាយមនុស្សដំបូងដែលទ្រង់បង្កើតមក ហើយជាជីវិតមួយដែលរស់នៅ ពោរពេញទៅដោយសុភមង្គល និងសប្បាយរីករាយជាមួយទ្រង់។ ប៉ុន្តែពួកគេបែរជាជ្រើសរើស ការមិនស្ដាប់បង្គាប់ព្រះ ហើយស្ដាប់សំលេងពីអារក្សសាតាំងវិញ។ ចាប់តាំងពីពេលនោះមក វិញ្ញាណរបស់ពួកគេត្រូវស្លាប់ ហើយពួកគេបាត់បង់នៅភាពស្និតស្នាលជាមួយនឹងព្រះ។

**ណារី:** ចាស បងប្អូនស្រ្តី បន្ទាប់ពីអាដាំ និងអេវ៉ា ជ្រើសរើសផ្លូវនៃអំពើបាប ដោយមិនស្ដាប់បង្គាប់ព្រះ មនុស្សទាំងអស់បានកើតមកជាប់មានអំពើបាបមកជាមួយ ដូចជាពួកគេទាំងពីរនាក់នោះដែរ។ យើងរាល់គ្នាមានបាប ហើយផលនៃអំពើបាបនោះគឺជាសេចក្ដីស្លាប់។ នៅក្នុងព្រះគម្ពីររ៉ូម ៣:២៣ បានប្រាប់ថា “ **គ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ**”។ ហើយនៅក្នុងព្រះគម្ពីររ៉ូម៦:២៣ បានប្រាប់ថា “ **ដ្បិតលទ្ធផលនៃបាប គឺសេចក្ដីស្លាប់**”។

**បូផា:** ចាស បងប្អូនស្រ្តី នៅក្នុងព្រះគម្ពីរបានប្រាប់យើងថា អារក្សសាតាំងគឺជាស្ដេចនៃភាពងងឹត ដែលក្នុងកណ្ដាប់ដៃរបស់វា មានតែសេចក្ដីស្លាប់។ គំរោងការរបស់វា មិនគ្រាន់តែធ្វើអោយយើងបះបោរប្រឆាំងនឹងព្រះប៉ុណ្ណោះទេ វាថែមទាំងនាំយើងចូលទៅឋាននរកជាមួយនឹងវាទៀតផង ដូច្នេះហើយ យើងនឹងឆ្លងកាត់សេចក្ដីស្លាប់អស់កល្បជានិច្ច។

**ណារី:** ចាស បងប្អូនស្រ្តី ឥឡូវនេះ យើងទាំងពីរនាក់នឹងប្រាប់បងប្អូនពីវិធីដែលទ្រង់ផ្លាស់ប្រែជីវិតរបស់អ្នក ហើយនេះជាដំណឹងយ៉ាងអស្ចារ្យមួយសំរាប់អ្នក។ នៅក្នុងព្រះគម្ពីរយ៉ូហាន៣:១៦ "**ព្រះជាម្ចាស់ស្រលាញ់មនុស្សខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ**"។ ហើយនៅក្នុងព្រះគម្ពីរ១យ៉ូហាន៣:៨ បានប្រាប់ទៀតថា " **អ្នកណាប្រព្រឹត្តអំពើបាប អ្នកនោះកើតចេញពីមារ ដ្បិតមារបានប្រព្រឹត្តអំពើបាប តាំងពីដើមរៀងមក។ ព្រះបុត្រារបស់ព្រះជាម្ចាស់បានយាងមក ដើម្បីរំលាយកិច្ចការរបស់មារ**"។

**បូផា:** ចាស បងប្អូនស្រ្តី ហើយនៅព្រះគម្ពីរយ៉ូហាន ១០:១០ បានប្រាប់ថា " **ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីអោយមនុស្សលោកមានជីវិត ហើយអោយគេមានជីវិតពេញបរិបូណ៌**"។ ជីវិតដែលពេញបរិបូណ៌ គឺជាជីវិតដែលពេញដោយសេចក្តីជំនឿលើព្រះ ដើម្បីអោយយើងមានចិត្តក្លាហានក្នុងការប្រឈមមុខនឹងឧបសគ្គគ្រប់យ៉ាង ដែលកើតឡើងចំពោះយើងជារៀងរាល់ថ្ងៃ។ ជាជីវិតដែលផ្តល់អោយយើងមានសង្ឃឹមក្នុងថ្ងៃអនាគត ដោយគ្មានភាពភ័យខ្លាច និងអស់សង្ឃឹម។

**ណារី:** ចាស មិនតែប៉ុណ្ណោះ ជីវិតដែលពេញបរិបូណ៌ ដែលព្រះយេស៊ូបានប្រទានអោយយើង គឺជាជីវិតមួយដែលផ្តល់អោយយើងនូវសេចក្តីអំណរ ទោះបីជាក្នុងកាលៈទេសៈបែប

ណាក៏ដោយ ហើយក៏ជាជីវិតដែលពេញទៅដោយសេចក្តីសុខសាន្តជាមួយព្រះ ជាមួយខ្លួនឯង និងជាមួយអ្នកដទៃផងដែរ។

**បូផា:** ចាស បងប្អូនស្រ្តី សូមបងប្អូនចងចាំសំដីដែលខ្ញុំបាននិយាយពេលនេះថា សូមជឿលើព្រះរាជបុត្រារបស់ព្រះចុះ ថ្វាយជីវិតដល់ទ្រង់ ហើយតទល់ជាមួយនឹងសេចក្តីល្បួងទាំងប៉ុន្មានរបស់អារក្ស។ សូមកុំស្តាប់បង្គាប់សំលេងរបស់វា ដែលតែងតែខ្សិបដាក់ត្រចៀកអ្នកថា “ ចូរសំលាប់ខ្លួនទៅ នោះរឿងអ្វីៗក៏ចប់ដែរ”។ សូមបងប្អូនបណ្តេញសំលេងទាំងអស់នោះចេញដោយនៅក្នុងព្រះនាមព្រះយេស៊ូគ្រីស្ទ នោះវានឹងរត់ជាសក្រញុាំទៅ។

**ណារី:** បងប្អូនស្រ្តី ព្រះបានមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរអេសេគាល ៣៣:១១ថា “ **យើងជាព្រះដែលមានជីវិតគង់នៅ យើងមិនសប្បាយចិត្តនឹងអោយមនុស្សអាក្រក់ស្លាប់ទេ តែយើងចង់ឃើញគេកែប្រែកិរិយាមារយាទ ដើម្បីអោយបានរស់រានមានជីវិត។**”

**បូផា:** បងប្អូនស្រ្តី ព្រះអង្គស្រលាញ់យើង ហើយទ្រង់ស្រលាញ់ជីវិតរបស់យើងផងដែរ។ សេចក្តីស្លាប់គឺជាលទ្ធផលនៃអំពើបាប ប៉ុន្តែវិញ្ញាណអាក្រក់ដែលខ្ញុំបានបញ្ជាក់ពីមុនមកនោះគឺវាស្រលាញ់សេចក្តីស្លាប់វិញ។ ដូច្នេះ បងប្អូនស្រ្តី ខ្ញុំមានដំណឹងល្អមួយចង់ប្រាប់បងប្អូនថាព្រះយេស៊ូជាជីវិត សូមចូលទៅកាន់ទ្រង់ នោះទ្រង់នឹងប្រទានជីវិតដល់អ្នករាល់គ្នា ដ្បិតទ្រង់មានអំណាចឈ្នះលើសេចក្តីស្លាប់។

**ណារី:** ចាស នៅក្នុងព្រះគម្ពីរយ៉ូហាន ១១:២៥-២៦ បានប្រាប់ថា “ **ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា « ខ្ញុំហ្នឹងហើយ ដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្តល់អោយគេមាន**

**ជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្តីនេះឬទេ?”**

**បូផា:** ចាស បងប្អូនស្រ្តី នៅពេលនេះ ខ្ញុំសូមលើកទឹកចិត្តបងប្អូនថា ទោះបីជាបងប្អូនមានបញ្ហានៅក្នុងជីវិតយ៉ាងណាក៏ដោយ សូមកុំគិតខ្លីរហូតដល់សំលាប់ខ្លួនអោយសោះ។ សូមស្តាប់នូវព្រះបន្ទូលរបស់ព្រះ ដែលទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរម៉ាថាយ ១១:២៨ ថា “ **អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានសំរាក”។**

**ណារី:** ចាស សូមបងប្អូនងាកមកឯទ្រង់ និងថ្វាយគ្រប់ទាំងការលំបាករបស់អ្នកដល់ទ្រង់ នោះទ្រង់នឹងជួយសង្គ្រោះអ្នក និងបណ្តេញវិញ្ញាណដែលប្រទាញអ្នកអោយស្អប់ខ្លួនឯងនោះចេញ។ នេះជាព្រះបន្ទូលសន្យារបស់ទ្រង់ចំពោះអ្នក។ បងប្អូនស្រ្តី តើអ្នកចង់ជ្រើសរើសជីវិតមួយដែលដើរជាមួយព្រះគ្រីស្ទដែរឬអត់?

**បូផា:** ចាស យើងខ្ញុំសង្ឃឹមថា បងប្អូននឹងទទួលទ្រង់។ ឥឡូវសូមអោយខ្ញុំអធិស្ឋានសំរាប់អ្នក “ **ឪព្រះវរបិតាអើយ កូនអរគុណទ្រង់ ដែលទ្រង់បានប្រទានជីវិតមកទូលបង្គំ គឺជាជីវិតអស់កល្បជានិច្ច តាមរយៈព្រះរាជបុត្រារបស់ទ្រង់។ ព្រះអង្គអើយ សូមប្រទានពរដល់បងប្អូនស្រ្តី និងប្រិយមិត្តអ្នកស្តាប់ទាំងអស់ នៅពេលដែលពួកគាត់មានការល្បួងនាំចិត្តពួកគាត់នោះ សូមទ្រង់បានជួយអោយពួកគាត់បានទុកចិត្តទ្រង់ និងព្រះបន្ទូលសន្យារបស់ទ្រង់ ដែល**

**ទ្រង់បានមានព្រះបន្ទូលថានឹងគង់ជាមួយពួកគាត់គ្រប់ពេលទាំងអស់ ទ្រង់មិនដែលបោះបង់ពួកគាត់ចោលឡើយ។ កូនសូមអរព្រះគុណទ្រង់ ហើយកូនសូមទូលថ្វាយរាល់ទាំងបងប្អូនកូនទាំងអស់ នៅក្នុងព្រះហស្តដ៏មានគ្រប់ទាំងអំណាចព្រះចេស្តា ព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ទ។ អាមែន!**

## កំណាប់មរតក

**ណារីៈ** ចាស បងប្អូនស្ត្រី កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមបានដល់ពេលវេលា ដែលត្រូវគោរពលាដល់បងប្អូនស្ត្រីហើយ។ ចាស យើងទាំងពីរនាក់សង្ឃឹមថា ពីកម្មវិធីយើងនៅថ្ងៃនេះ នឹងបានលើកទឹកចិត្តដល់បងប្អូនទាំងអស់គ្នា ហើយក៏សង្ឃឹមថា បងប្អូននឹងយកអ្វីដែលយើងខ្ញុំបានជំរាបជូន នៅថ្ងៃនេះទៅពិចារណាផងដែរ។ ប្រសិនបើបងប្អូនមានចំងល់ បងប្អូនអាចទំនាក់ទំនងមកកាន់តាមរយៈទូរសព្ទលេខ ០៩២ ៦០ ៦០ ៥១ និង ០៨៨ ៤៥៦ ៤៤ ៥៥។

**បូផាៈ** កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ផលិតដោយអង្គការគ្រេសន៍វើលកម្ពុជា។ កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម សូមលំអោនកាយជំរាបលា ប្រិយមិត្តអ្នកស្តាប់ត្រឹមប៉ុណ្ណេះសិន។ សន្យាថានឹងវិលមកជួបគ្នាម្តងទៀត នៅសប្តាហ៍ក្រោយ តាមពេលវេលាដដែល ម៉ោងដដែល។ សូមព្រះប្រទានពរ!!